00582584

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 08 / 2010
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ/No: D264/2/6

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៤២)**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គីមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន័យ ថុល |
| | ចៅក្រម Catherine MARCHI-UHEL |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ |

---

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់
សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ
ដោយមូលហេតុរំលោភនីតិវិធី (D264/1)**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Mahdev MOHAN

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

**សហមេធាវីការពារក្តីជនត្រូវចោទ**
ផាត់ ពៅស៊ាង

Lyma NGUYEN
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN-NZEPA
ឡៅ ជុនធី
ស៊ិន សុវ៉ន
ហុង គឹមសួន
គង់ ពិសី
Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Partirck BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Pascal AUBOIN
យុង ផានិត

Diana ELLIS QC

<u>**ដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានអ្នកតំណាង**</u>

00582586



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភលើនីតិវិធី ដែលដាក់ដោយអ្នកស្រី អៀង ធីរិទ្ធ[១]" ("បណ្តឹងឧទ្ធរណ៍សុំមោឃភាព" និង "បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី" ដែលហៅរួមថា "បណ្តឹងឧទ្ធរណ៍") ដាក់នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទ អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") "បដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភលើនីតិវិធី ដែលដាក់ដោយអ្នកស្រី អៀង ធីរិទ្ធ[២]" ("ដីកាសម្រេចសុំមោឃភាពដែលត្រូវបានជំទាស់" និង "ដីកាសម្រេចស្តីពីការរំលោភលើនីតិវិធីដែលត្រូវបានជំទាស់" ដែលហៅរួមថា "ដីកាដែលត្រូវបានជំទាស់") ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងបានជូនដំណឹងដល់ភាគី នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០។

## I. ការពិចារណាបឋម

១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្តល់សេចក្តីសម្រេចតែមួយគត់ នៅក្នុងដីកាសម្រេចស្តីពីការសុំមោឃភាពដែលត្រូវបានជំទាស់ និងនៅក្នុងដីកាសម្រេចស្តីពីការរំលោភលើនីតិវិធីដែលត្រូវបានជំទាស់ដែលជាលទ្ធផល ដីកាដែលត្រូវបានជំទាស់

---

[១] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង "ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភលើនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ" (D263/1) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D263/2/1 ("បណ្តឹងឧទ្ធរណ៍សុំមោឃភាព") និងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង "ដីកាសម្រេចបដិសេធលើសំណើសុំមោឃភាព និងសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភលើនីតិវិធី ដែលធ្វើឡើងដោយជនត្រូវចោទ អៀង ធីរិទ្ធ" (D264/1) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D264/2/1 ("បណ្តឹងឧទ្ធរណ៍ដោយមូលហេតុរំលោភលើនីតិវិធី") (ហៅរួមថា "បណ្តឹងឧទ្ធរណ៍")។

[២] ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភលើនីតិវិធីឡើងដោយ អៀង ធីរិទ្ធ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងជូនដំណឹងនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ឯកសារ D263/1 ("ដីកាសម្រេចសុំមោឃភាពដែលត្រូវបានជំទាស់") និងដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភលើនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងជូនដំណឹងនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ឯកសារ D264/1 ("ដីកាសម្រេចស្តីពីការរំលោភលើនីតិវិធីដែលត្រូវបានជំទាស់") (ហៅរួមថា "ដីកាដែលត្រូវបានជំទាស់")។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ទាំងពីរនេះ ត្រូវបានយោងជារួមនៅក្នុងសារណាក្រោយៗបន្តបន្ទាប់ទៀត ដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងនេះ នៅក្នុងសាលដីកាដោយឡែកពីគ្នា ដើម្បីជៀសវាងភាពភាន់ច្រឡំ។ នៅក្នុងសាលដីកានេះ អង្គបុរេជំនុំជម្រះសម្រេចតែទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធីតែប៉ុណ្ណោះ[៣]។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ អ្នកស្រី អៀង ធីរិទ្ធ ("ជនត្រូវចោទ ឬ "ដើមបណ្តឹងឧទ្ធរណ៍") បានដាក់សំណើចំនួនពីរ៖ (i) "សំណើទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពលើកិច្ចស៊ើបសួរ" ("សំណើសុំមោឃភាព"[៤]) និង (ii) "សំណើរបស់មេធាវីការពារក្តី ស្នើសុំផ្អាកនីតិវិធីដោយមូលហេតុរំលោភលើនីតិវិធី" ("សំណើស្តីពីការរំលោភលើនីតិវិធី")[៥]។ សំណើស្តីពីការរំលោភលើនីតិវិធី ស្នើសុំឱ្យព្យួរកិច្ចស៊ើបសួរដោយមូលហេតុថា ការរំលោភលើនីតិវិធីរបស់តុលាការបានធ្វើឱ្យជនត្រូវចោទមិនអាចទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌មួយបានទេ។ សហមេធាវីការពារក្តីផ្អែកទឡ្ហីករណ៍នេះទៅលើកត្តាមួយចំនួនដូចជា៖

> ភាពគ្មានអនាគតិនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ក.ស.ច.ស ពុំមានឯករាជ្យដាច់ចេញពីការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") ភាពមិនប្រក្រតីខាងនីតិវិធីធ្ងន់ធ្ងរនៅក្នុងកិច្ចស៊ើបសួររបស់ ក.ស.ច.ស និងការអនុវត្តនៅ ក.ស.ច.ស គ្មានតម្លាភាព និងមិនអាចជឿទុកចិត្តបាន[៦]។

---

[៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ៤១) ឯកសារ D263/2/6 ("សាលដីកាលើសំណើសុំមោឃភាព")។

[៤] សំណើទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃកម្មកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D263 (សំណើសុំមោឃភាព)។

[៥] សំណើរបស់មេធាវីការពារក្តី ស្នើសុំផ្អាកនីតិវិធីដោយមូលហេតុរំលោភលើនីតិវិធី ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D264 (សំណើសុំស្តីពីការរំលោភលើនីតិវិធី)។

[៦] សំណើសុំស្តីពីការរំលោភលើនីតិវិធី កថាខណ្ឌ១។

៣. នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ស.ច.ស បានចេញដីកាសម្រេចដូចគ្នាទាំងស្រុងពីរ ដែលបានប្រកាសថា "មិនមានអ្វីដែលអាចផ្តល់យុត្តិកម្ម" លើបណ្តឹងសុំមោឃភាពចំពោះនីតិវិធី ឬព្យួរកិច្ចស៊ើបសួរណាមួយទេ ពីព្រោះគ្មាន "កំហុសនីតិវិធី" ឬ "ការប៉ះពាល់សិទ្ធិណាមួយរបស់មេធាវីការពារក្តី" ឡើយ[៧]។ ដីកាសម្រេចស្តីពីការរំលោភលើនីតិវិធីដែលត្រូវបានជំទាស់នេះ បានបដិសេធមូលដ្ឋានដែលលើកឡើងនៅក្នុងសំណើស្តីពីការរំលោភលើនីតិវិធី ដោយឈរលើមូលដ្ឋានថា៖

(i) ការវាយតម្លៃលើការងាររបស់បុគ្គលិកណាមួយ "មិនមានជាប់ពាក់ព័ន្ធជាមួយនឹងសិទ្ធិរបស់ភាគីទាល់តែសោះ" ពីព្រោះវាជាការវាយតម្លៃលើការងារ ដែលធ្វើឡើងដោយ ស.ច.ស អន្តរជាតិ ដែលជា"ប្រធានស្ថាប័ន" ហើយ "ដូច្នេះ ការចោទប្រកាន់ថាមាន 'ការជ្រៀតជ្រែកចូលក្នុងកិច្ចការ' គឺគ្មានមូលដ្ឋានត្រឹមត្រូវទេ"[៨]។

(ii) សហមេធាវីការពារក្តីមិនអាចបង្ហាញថា សុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រីមានឥទ្ធិពលមកលើ "សេចក្តីសម្រេច ឬកិច្ចនានារបស់ចៅក្រម... ដែលគេអាចរិះគន់បានខាងទស្សនៈតុលាការសុទ្ធសាធ" នោះឡើយ[៩]។

(iii) សហមេធាវីការពារក្តីបានយល់ខុសទៅលើសេចក្តីសម្រេចរបស់ស.ច.ស លើរឿងឃ្លាំងផ្ទុកឯកសាររួម ទាក់ទងនឹង "គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាង"[១០] ហើយ

(iv) នៅក្នុងដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន គេឃើញមាន "យោបល់លើកឡើងស្តីពីទំហំនៃភស្តុតាង" ដែលមិនត្រូវបានហាមឃាត់ដោយសារភាពអនាគតិរបស់ចៅក្រមនោះទេ[១១]។

---

[៧] ដីកាសម្រេចស្តីពីការរំលោភនីតិវិធីដែលត្រូវបានជំទាស់ កថាខណ្ឌ៤២។

[៨] ដីកាសម្រេចស្តីពីការរំលោភនីតិវិធីដែលត្រូវបានជំទាស់ កថាខណ្ឌ៣៧។

[៩] ដីកាសម្រេចស្តីពីការរំលោភនីតិវិធីដែលត្រូវបានជំទាស់ កថាខណ្ឌ៣៨។

[១០] ដីកាសម្រេចស្តីពីការរំលោភនីតិវិធីដែលត្រូវបានជំទាស់ កថាខណ្ឌ៣៩-៤០។

[១១] ដីកាសម្រេចស្តីពីការរំលោភនីតិវិធីដែលត្រូវបានជំទាស់ កថាខណ្ឌ៤១។

៤. នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់បណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី លើកឡើងលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ចំនួនប្រាំពីរ ប្រឆាំងនឹងដីកាសម្រេចស្តីពីការរំលោភលើនីតិវិធី ដែលមូលដ្ឋានទាំងនោះរួមមាន៖

(i) ស.ច.ស មានកំហុសនៅក្នុងការបកស្រាយរបស់ខ្លួនទៅលើច្បាប់ ដោយដកស្រង់សេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ធ្វើជាសំអាងផ្លូវច្បាប់ ហើយមិនអើពើចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលជាស្ថាប័នយុត្តិសាស្ត្រមានអធិកភាព[១២]។

(ii) ស.ច.ស បានអនុវត្តមិនត្រឹមត្រូវដោយយកបទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់បណ្តឹងជិតចិត្ត មកប្រើប្រាស់ចំពោះបណ្តឹងសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុកំហុសនីតិវិធី[១៣]។

(iii) ស.ច.ស ខកខានក្នុងការឆ្លើយទៅលើទឡ្ហីករណ៍លម្អិតដែលលើកឡើងដោយសហមេធាវីការពារក្តីនៅក្នុងសំណើ[១៤]។

(iv) ស.ច.ស បកស្រាយវិធាន៥៦ នៃវិធានផ្ទៃក្នុងមិនត្រឹមត្រូវ[១៥]។

(v) ស.ច.ស ខកខានក្នុងការឆ្លើយទៅលើទឡ្ហីករណ៍របស់សហមេធាវីការពារក្តី ដែលលើកឡើងថា “ក្រុមថតខ្សែភាពយន្តបានថតសាក្សីផ្ទៃក្នុង ដោយសម្ងាត់” ដែល “បង្ហាញបញ្ជាក់បន្ថែមពីការបកស្រាយមិនត្រឹមត្រូវ ទៅលើវិធាន៥៦(២)(ខ) នៃវិធានផ្ទៃក្នុង”[១៦]។

(vi) ស.ច.ស ខកខានក្នុងការបដិសេធថា បានទទួលឯកសារមួយពីអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព”)[១៧] ហើយ

---

[១២] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៥។

[១៣] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ១៨។

[១៤] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ២៧។

[១៥] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ៣៩។

[១៦] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ៤៨ និង៥២។

[១៧] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ៥៤។

(vii) នៅក្នុងកថាខណ្ឌទី២០ នៃដីកាសម្រេចស្តីពីការរំលោភលើនីតិវិធី មានការលើកឡើងពីការពិចារណាមួយរបស់ ស.ច.ស អន្តរជាតិ ដោយគ្មានការចូលរួមពី ស.ច.ស ជាតិ[១៨]។

៥. បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី ស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចស្តីពីការរំលោភលើនីតិវិធីនេះ ហើយស្នើឱ្យមានសវនាការដេញដោលផ្ទាល់មាត់មួយ ដើម្បីស្តាប់សារណានានា និងដើម្បីទទួលយកភស្តុតាងសម្រាប់ "បញ្ជាក់ពីសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយលោក Bastin និងលោកចៅក្រម Lemonde"[១៩]។

៦. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីសន្និដ្ឋានរួមរបស់សហព្រះរាជអាជ្ញា តបទៅបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង 'ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំឮ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភលើនីតិវិធីដែលដាក់ដោយអ្នកស្រី អៀង ធីរិទ្ធ'" ("សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា")[២០] ដែលត្រូវបានធ្វើឡើងក្នុងគោលបំណងឆ្លើយតបស្នើគ្នាទៅនឹងបណ្តឹងឧទ្ធរណ៍សុំធ្វើមោឃភាព និងបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី[២១]។ សហព្រះរាជអាជ្ញាស្នើថា អង្គបុរេជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍ទាំងពីរនេះ ហើយតម្កល់ដីកាសម្រេចរបស់ ស.ច.ស ដោយមូលហេតុថា បណ្តឹងឧទ្ធរណ៍ទាំងនេះ ក៏ដូចជាសារណាដែលមាននៅក្នុងនោះ៖

(i) ផ្តល់ភស្តុតាងមិនអាចឱ្យជឿបាន មិនចង្អុលពីអ្វីដែលគេចង់អះអាងបញ្ជាក់ និង/ឬ មិនបានបង្ហាញឱ្យឃើញពីការរំលោភណាមួយលើសិទ្ធិរបស់ជនត្រូវចោទ។

---

[១៨] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ៦១។

[១៩] បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ៨០។

[២០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង "ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំឮ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ" ឯកសារ D263/1 នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។

[២១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤។

(ii) ខកខានមិនបានបំពេញនូវបន្ទុកដ៏ខ្ពស់បំផុតអំពីការរំលោភទ្រឹស្តីនៃដំណើរការ និងបទដ្ឋានសម្រាប់មោឃភាពនៃកិច្ចស៊ើបសួរទាំងអស់ ដែលជាដំណោះស្រាយតាមផ្លូវតុលាការ ហួសប្រមាណបម្រុងទុកសម្រាប់កាលៈទេសៈធ្ងន់ធ្ងរបំផុតទេ។

(iii) លើកអំពីយោបល់ផ្សេងៗដែលមិនមានមូលដ្ឋានច្បាស់លាស់ ទាក់ទិននឹងកង្វះសហប្រតិបត្តិការរវាង ស.ច.ស ជាតិ និងអន្តរជាតិ ដែលជាបញ្ហាមិនពាក់ព័ន្ធ មិនសមហេតុផល ឬក៏គ្រាន់បើជាងដែរ បើសិនជាគេបានលើកឡើងអំពីយន្តការដោះស្រាយវិវាទចំពោះ ស.ច.ស ដែលគេអាចរកបានក្រោមវិធាន៧២ នៃវិធានផ្ទៃក្នុង និង

(iv) ខកខានមិនបានបញ្ជាក់ថា ស.ច.ស បានអនុវត្តខុស ចំពោះច្បាប់ដែលកំពុងគ្រប់គ្រងក្នុងការបង្កើតដីកាសម្រេចរបស់ខ្លួនទេ[២២]។

៧. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីសម្រេចរបស់ខ្លួនមួយដើម្បីដោះស្រាយបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងបង្គាប់ឲ្យភាគីដាក់សារណាតប"[២៣] ដោយបដិសេធសំណើរបស់សហមេធាវីការពារក្តីរបស់ជនត្រូវចោទដែលស្នើសុំឲ្យមានសវនាការសាធារណៈនោះ ហើយអង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យសហមេធាវីការពារក្តីដាក់ចម្លើយតប ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[២៤]។

៨. នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់ "ចម្លើយតបដូចគ្នាមួយ តបទៅនឹងសេចក្តីសន្និដ្ឋានរួមរបស់សហព្រះរាជអាជ្ញា លើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចស្តីពីការរំលោភលើនីតិវិធី និងមោឃភាព" ("ចម្លើយតបរបស់មេធាវីការពារក្តី")[២៥]។ ចម្លើយតបរបស់មេធាវីការពារក្តីចោទប្រកាន់ថា៖ (i) រាល់កិច្ចស៊ើបសួរទាំងអស់ត្រូវចាត់ថា

---

[២២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣។

[២៣] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីណែនាំឲ្យធ្វើការឆ្លើយតប ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ឯកសារ D264/2/3។

[២៤] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៤ មាត្រា៨.៤។

[២៥] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសេចក្តីសន្និដ្ឋានតបរួមរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីលើដីកាសម្រេចអំពីការរំលោភនីតិវិធី និងដីកាសម្រេចបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី១៩ មីនា ឆ្នាំ២០១០ ឯកសារ D263/2/4 (ចម្លើយតបរបស់មេធាវីការពារក្តី)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

មោឃៈ ដោយសារកំហុសនីតិវិធីបានជះឥទ្ធិពលលើកិច្ចស៊ើបអង្កេតទាំងមូល[២៦] ហើយថា សហព្រះរាជអាជ្ញាមានការភាន់ច្រឡំទៅលើ "សំណើដែលស្នើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងពីរនោះ"[២៧] (ii) ស.ច.ស ខកខានមិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ចំពោះដីកាដែលត្រូវបានជំទាស់ទាំងនោះ ដែលរំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌មួយ[២៨] (iii) សហព្រះរាជអាជ្ញាខកខានក្នុងការបដិសេធថា មានឯកសារមួយត្រូវបានផ្លាស់ប្តូរគ្នារវាង ក.ស.ព និង ក.ស.ច.ស[២៩] ហើយ (iv) ក.ស.ច.ស មិនបាន "គ្រប់គ្រងឲ្យបានតឹងរឹង" ទៅលើក្រុមថតខ្សែភាពយន្តឯកសារនោះទេ[៣០]។

៩. នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចស្តាពរលើបណ្តឹងឧទ្ធរណ៍ ដោយបញ្ជាក់ថា "សាលដីកាដែលមានសំអាងហេតុទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នោះ នឹងដាក់ជូនដល់ភាគីនៅក្នុងពេលសមស្រប។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះជាឯកច្ឆន្ទ÷**

**សម្រេច** ទទួលយកបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី។

**សម្រេច** លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានដែលមានចែងនៅក្នុងសំណើស្តីពីការរំលោភនីតិវិធី។

**ច្រានចោល** សំណើស្តីពីការរំលោភនីតិវិធី ចាត់ទុកថាឥតបានការ"[៣១]។

---

[២៦] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៥។

[២៧] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១២។

[២៨] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៣-១៥។

[២៩] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៦-១៧។

[៣០] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៨-២០។

[៣១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D264/2/5។

អង្គបុរេជំនុំជម្រះ ... PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00582593



**សំអាងហេតុសម្រាប់សាលដីកានេះ**

## III. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

១០. សំណើស្តីពីការរំលោភលើនីតិវិធី និងបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី ត្រូវបានធ្វើឡើងដោយផ្អែកលើយុត្តាធិការរបស់តុលាការនេះដែលខ្លួនមានជាស្រេច ដើម្បីធានាថា បុគ្គលនានាទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌មួយ។ ទ្រឹស្តីស្តីពីការរំលោភលើនីតិវិធី ដែលមានដើមកំណើតនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូ នាពេលបច្ចុប្បន្ននេះត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃច្បាប់អន្តរជាតិ និងជាការអនុវត្តអន្តរជាតិ ដើម្បីធានាថា ការរំលោភបំពានធ្ងន់ធ្ងរនានាលើកិច្ច ឬលើនីតិវិធីដែលមិនត្រឹមត្រូវ ឬខុសច្បាប់ទាំងស្រុងនោះ មិនត្រូវបានអនុញ្ញាតឲ្យមាន ដើម្បីលុបចោលនូវសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានផ្តល់ឲ្យជនត្រូវចោទ ឬជនជាប់ចោទនៅចំពោះមុខតុលាការនោះទេ[៣២]។

១១. សហចៅក្រមស៊ើបអង្កេត មិនបានពិចារណាបញ្ហាយុត្តាធិការនេះទេនៅក្នុងដីកាសម្រេចរបស់ខ្លួន ហើយត្រូវបានអង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការតាមការសន្មត ដើម្បីដោះស្រាយសំណើនេះ។

១២. គេកត់សម្គាល់ឃើញថា សំណើសុំព្យួរកិច្ចស៊ើបសួរអាចត្រូវបានពិចារណាថាជាសំណើសុំឲ្យចេញ "ដីកាសម្រេច" មួយ ដោយអនុលោមតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ពីព្រោះនេះជាសំណើសុំឲ្យចេញដីកាសម្រេចស្តីពី "កិច្ចស៊ើបសួរ"[៣៣] ដោយធ្វើការបកស្រាយពាក្យ "កិច្ចស៊ើបសួរ" នេះក្នុងន័យទូលំទូលាយបំផុត។ អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយលើភាពមិនស្របគ្នាដែលអាច

---

[៣២] *រឿងក្តី Jean-*Bosco *Barayawiza តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿង ICTR-97-19-AR72 "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩ (សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Barayagwiza*) កថាខណ្ឌ៤។

[៣៣] វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

មានរវាងវិធាន៧៤(៣)(ខ)[៣៤] និងវិធាន ៥៥(១០)[៣៥] នៃវិធានផ្ទៃក្នុង ហើយដូច្នេះ សំណើបែបនេះ នឹងមិនបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ដោយជនត្រូវចោទទេ។

១៣. ដូចគ្នានេះផងដែរ សហចៅក្រមស៊ើបអង្កេតក៏អាចពិចារណា "សំណើសុំឲ្យរកិច្ចស៊ើបសួរ" នៅក្នុងដែនកំណត់ទូទៅនៃពាក្យបណ្ដឹងណាមួយ ដែលស្ថិតនៅក្រោមមាត្រា៣៣ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្នុងនោះចែងពាក់ព័ន្ធថា "ការជំនុំជម្រះក្ដីត្រូវតែយុត្តិធម៌" ហើយត្រូវប្រព្រឹត្តទៅ "ដោយគោរពយ៉ាងពេញលេញទៅលើសិទ្ធិរបស់ជនជាប់ចោទ..."[៣៦]។ សម្រាប់គោលបំណងរបស់តុលាការនេះ បទប្បញ្ញត្តិនៃមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[៣៧] អាចយកមកអនុវត្តបាននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ បន្ថែមលើនេះ មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផ្ដល់ឱ្យនូវសិទ្ធិមានអធិកភាពដែលនឹងធ្វើជាយុត្តិសាស្ត្រសម្រាប់កិច្ចដំណើរការនីតិវិធីជាតិ។ បទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងផងដែរ។

---

[៣៤] វិធាន៧៤(៣)(ខ) កំណត់លទ្ធភាពរបស់ជនត្រូវចោទក្នុងការដាក់បណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងដីកាសម្រេចរបស់ ក.ស.ច.ស បដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ។

[៣៥] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D273/3/5 កថាខណ្ឌ៩ ដកស្រង់ពីសាលដីកាលើភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេច អំពីការប្រើប្រាស់ចម្លើយដែលបានមកឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារ D/130/10/12 កថាខណ្ឌ១៧។

[៣៦] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ២០០១ រួមជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា៣៣ថ្មី។

[៣៧] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្ដីសម្រេចចិត្តលេខ 2200A [XX1] របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ("ICCPR") មាត្រា១៤ និង១៥។

១៤. ដោយកត់សម្គាល់ឃើញថា ច្បាប់កម្ពុជាមិនបានផ្តល់ឱ្យនូវយន្តការដោះស្រាយលើការរំលោភលើកិច្ចស៊ើបសួរទេនោះ អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចអនុវត្តតាមយុត្តិសាស្ត្រអន្តរជាតិ សន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងពាក្យបណ្តឹងបែបនេះ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលថាតើអង្គហេតុ និងស្ថានភាពនៃបណ្តឹងឧទ្ធរណ៍ទាមទារឱ្យមានការបកស្រាយទូលំទូលាយទៅលើវិធាន៧៤(៣) នៃវិធានផ្ទៃក្នុងដែរឬទេ ដោយគិតពិចារណាទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌មួយ។ ការពិចារណាលើសលុបនៅក្នុងរាល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងនេះ ដូចមានចែងនៅក្នុងវិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍លើកឡើងនូវបញ្ហាធ្ងន់ធ្ងរមួយនៃភាពយុត្តិធម៌ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការពិចារណាដោះស្រាយបណ្តឹងនេះ។

១៥. ដីកាសម្រេចត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០។ សេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០[៣៨] ហើយសារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងនៅក្នុងពេលកំណត់ត្រឹមត្រូវ។

១៦. បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភលើនីតិវិធី ត្រូវបានដាក់ដោយអនុលោមតាមវិធាន៧៥ នៃវិធានផ្ទៃក្នុង។ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

## V. សេចក្តីសន្និដ្ឋានបឋម

១៧. គេត្រូវកត់សម្គាល់ថា នៅក្នុងសំណុំរឿងមួយនេះ មានទំនាស់រួចជាស្រេចទៅហើយ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតដោះស្រាយការចោទប្រកាន់ពីការប្រព្រឹត្តិរបស់ខ្លួនផ្ទាល់ តែចៅក្រមម្នាក់

[៣៨] សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ លើដីកាបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរលើកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០។

ឬទាំងពីរនាក់។ បន្ថែមលើនេះ មិនមានបញ្ហាឆន្ទានុសិទ្ធិពាក់ព័ន្ធឡើយ ហើយភាគីជំទាស់តវ៉ាប្រឆាំងនឹងការសម្រេចរបស់តុលាការ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។

១៨. អង្គបុរេជំនុំជម្រះរកឃើញថា ដើម្បីភាពយុត្តិធម៌ដែលអាចត្រូវបានប៉ះពាល់ដោយទំនាស់ដែលមានរួចជាស្រេចនេះ បញ្ហានេះនឹងត្រូវពិចារណាជាថ្មីតែម្តង។ ដូច្នេះ វាមានភាពសមស្រប ដើម្បីដោះស្រាយបណ្តឹងនេះ ដោយចាត់ទុកថា ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើស្តីពីការរំលោភលើនីតិវិធីមកអង្គបុរេជំនុំជម្រះដោយផ្ទាល់តែម្តង ដោយមានឯកសារគាំទ្រដើមមកជាមួយផង។

## IV. បទដ្ឋាននៃការពិនិត្យឡើងវិញ

១៩. នៅក្នុងសំណើសុំរបស់ខ្លួនស្តីពីការបំពាននីតិវិធី សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានបញ្ជាក់ថា "មេធាវីការពារក្តីមានសិទ្ធិបង្ហាញពីតុល្យការនៃភវនីយហេតុដែលថា មានការរំលោភលើនីតិវិធីមែន"[៣៩]។

២០. តាមមាត្រា ៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២១ នៃវិធានផ្ទៃក្នុង ជនត្រូវចោទមានសិទ្ធិទទួលបានការការពារមួយចំនួន ដែលរាប់បញ្ចូលទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។ ដូចបានកត់សម្គាល់ខាងលើ[៤០] គ្មានបទប្បញ្ញត្តិណាមួយក្នុងវិធានផ្ទៃក្នុង ឬក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងយោងជាក់លាក់អំពីលទ្ធភាពនៃការផ្អាកនីតិវិធីក្នុងករណីដែលការបំពានលើសិទ្ធិរបស់ជនជាប់ចោទ ឬជនត្រូវចោទ មានភាពធ្ងន់ធ្ងរដែលរាំងស្ទះដល់ដំណើរការនីតិវិធីទាំងមូលឡើយ។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលបទដ្ឋានអន្តរជាតិ ដើម្បីកំណត់បទដ្ឋាននៃការពិនិត្យដែលអាចយកមកអនុវត្តបាន ដើម្បីពិចារណាថាតើមាន ឬមិនមានការបំពាននីតិវិធី។

២១. អង្គបុរេជំនុំជម្រះមិនត្រឹមតែមានកាតព្វកិច្ចគោរពតាមវិធាន ២១ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ប៉ុន្តែអង្គបុរេជំនុំជម្រះក៏ត្រូវផ្តល់សារៈសំខាន់ដ៏ធំធេងដល់ការគោរពសិទ្ធិមនុស្ស និងដំណើរការនីតិវិធី

---

[៣៩] សំណើសុំពាក់ព័ន្ធនឹងការរំលោភនីតិវិធី កថាខណ្ឌ ១៣។

[៤០] ចូរអាន កថាខណ្ឌ ១៤។



អង្គបុរេជំនុំជម្រះ
E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដែលត្រឹមត្រូវតាមច្បាប់ទាំងស្រុងផងដែរ។ អង្គបុរេជំនុំជម្រះឯកភាពតាមទស្សនៈដែលបានលើកឡើងនៅក្នុងសាលាក្តីដទៃទៀត ដែលតុលាការទាំងនោះបញ្ជាក់ថា "បញ្ហានៃការគោរពនីតិវិធីត្រឹមត្រូវតាមច្បាប់ មានវិសាលភាពធំជាងកាតព្វកិច្ចធានាការជំនុំជម្រះក្តី ដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ" ហើយជាពិសេស ក៏រួមបញ្ចូលទាំង "វិធីដែលភាគីត្រូវប្រព្រឹត្តក្នុងបរិបទនៃរឿងក្តីនីមួយៗផងដែរ" [៤១]។

២២. អនុលោមតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា ទ្រឹស្តីស្តីពីការរំលោភនីតិវិធីគឺជា "នីតិវិធីដែលអនុញ្ញាតឲ្យចៅក្រមអាចបដិសេធការអនុវត្តតាមយុត្តាធិការរបស់តុលាការ ក្នុងករណីដែលការអនុវត្តឆន្ទានុសិទ្ធិនេះអាចនាំឲ្យមានការបំពាន*ធ្ងន់ធ្ងរ* និង*ជាក់ស្តែង* ទៅលើសិទ្ធិជនជាប់ចោទ ហើយនឹងនាំឲ្យអន្តរាយដល់សុចរិតភាពរបស់តុលាការ" (សេចក្តីបញ្ជាក់បន្ថែម)[៤២]។ តុលាការអាចសំអាងទ្រឹស្តីស្តីពីការរំលោភនីតិវិធីថាជាឆន្ទានុសិទ្ធិ ហើយចៅក្រមអាចរកឃើញថា មានការរំលោភនីតិវិធី និងសម្រេចថា មិនអនុវត្តយុត្តាធិការរបស់ខ្លួន ដោយតម្កល់រឿងទុកឥតចាត់ការ ដែលមានអានុភាពបញ្ចប់នីតិវិធីទាំងស្រុង[៤៣]។

២៣. ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយោងទៅរកយុត្តិសាស្ត្រពីមុនរបស់ខ្លួនក្នុងរឿងក្តី *Barayagwiza* ហើយបានរកឃើញថា ខ្លួនអាចពិចារណាតែលើស្ថានភាពពីរប៉ុណ្ណោះ ដែលបង្កើតបានជាការបំពានធ្ងន់ធ្ងរ និងជាក់ស្តែងលើសិទ្ធិរបស់ជនជាប់ចោទ៖ (i) កាលណាមិនអាចធានាការជំនុំជម្រះដោយយុត្តិធម៌ជូនជនជាប់ចោទបាន ដោយសារការពន្យារពេល និង (ii) កាលណាកាលៈទេសៈនៃរឿងក្តីណាមួយបង្ហាញថា ការបន្តដំណើរការជំនុំ

---

[៤១] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Dragan Nikolic* IT-94-5-PT "សេចក្តីសម្រេចលើបណ្តឹងមេធាវីប្រឆាំងនិងការអនុវត្តយុត្តាធិការរបស់សាលាក្តី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០២ ("សេចក្តីសម្រេច *Nikolic* ") កថាខណ្ឌ ១១១។

[៤២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Barayagwiza* កថាខណ្ឌ ៧៤។

[៤៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Barayagwiza* កថាខណ្ឌ ៧៥ (យោង រឿងក្តី *Bell* ទល់នឹង *DPP* នៃប្រទេសចាម៉ៃកា [1985] AC 937): "តាមទ្រឹស្តីស្តីពីការរំលោភលើនីតិវិធី តុលាការមានអំណាចឆន្ទានុសិទ្ធិក្នុងការបដិសេធចោលបញ្ហា ដែលអាចនាំឲ្យមានការពន្យារពេលដែលមិនសមស្រប"។

ជម្រះជនជាប់ចោទនឹងបំពានលើស្មារតីយុត្តិធម៌របស់តុលាការ ដោយសារតែភាពមិនត្រឹមត្រូវ ឬ កំហុសឆ្គងក្នុងដំណាក់កាលមុនអង្គសេចក្តី។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបញ្ជាក់ថា "បទដ្ឋានជាធរមានបានបំភ្លឺបន្ថែមដោយបញ្ជាក់ថា តាមឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចសម្រេចមិនអនុវត្តយុត្តាធិការ "ក្នុងករណីដែលការអនុវត្តឆន្ទានុសិទ្ធិនោះ អាចនាំឱ្យមាន*ការបំពានធ្ងន់ធ្ងរ និងជាក់ស្តែងទៅលើសិទ្ធិរបស់ជនជាប់ចោទ* ហើយនឹងនាំឱ្យអន្តរាយដល់សុចរិតភាពរបស់តុលាការ"[៤៤]។

២៤. តុលាការបានប្រើបទដ្ឋានដ៏ខ្ពស់ នៅពេលដែលត្រូវកំណត់ថាតើការបំពានលើសិទ្ធិរបស់មេធាវីការពារអាច ឬមិនអាចចាត់ទុកថាជាការបំពានគ្រប់គ្រាន់ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបញ្ចប់ដំណើរការនីតិវិធី[៤៥]។ ក្នុងរឿងក្តី *Karadžic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ*ពិសេស* បានយោងទៅរកបទដ្ឋាននេះ ហើយបានសម្រេចថាបទដ្ឋានពិនិត្យត្រឹមត្រូវ (ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបញ្ជាក់ពីមុន) ពាក់ព័ន្ធនឹង"ការពិចារណាថាតើដើមបណ្តឹងឧទ្ធរណ៍បានទទួលរង*ប្រព្រឹត្តកម្មអាក្រក់ធ្ងន់ធ្ងរ* ឬថាតើមាន*ការបំពានជាក់ស្តែងដទៃទៀត* លើសិទ្ធិរបស់ជនជាប់ចោទដែរឬទេ" (សេចក្តីបញ្ជាក់បន្ថែម)[៤៦]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរំឭកថា "យុត្តិសាស្ត្រនេះមិនអនុញ្ញាតឱ្យទ្រឹស្តី ស្តីពីការរំលោភនីតិវិធីយកបទដ្ឋានទាបជាងនេះមកប្រើឡើយ ទោះបីជាបុគ្គលដែលរងការចោទប្រកាន់ពីកំហុសឆ្គងនោះជាអ្វីក៏ដោយ" [៤៧]។

២៥. តាមការពិចារណាខាងលើនេះ អង្គបុរេជំនុំជម្រះមិនយល់ស្របនឹងការអះអាងរបស់មេធាវីការពារក្តីថាអាចយកបទដ្ឋាននៃការបង្ហាញភស្តុតាងមកអនុវត្តបាន កាលណាទ្រឹស្តីស្តីពីការរំលោភនីតិវិធី

---

[៤៤] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* *Radovan Karadžic* IT-95-5/18-AR73.4, "សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Karadžic* ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកិច្ចព្រមព្រៀង Holbrooke" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Karadžic")* កថាខណ្ឌ ៤៥ ចូរអានកថាខណ្ឌ ៧៤, ៧៧ នៃសាលក្រម *Barayagwiza* ផងដែរ។

[៤៥] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* *Vijoslav Šešselj* IT-30-67-T, "សេចក្តីសម្រេចលើសំណើផ្ទាល់មាត់របស់ជនជាប់ចោទស្តីពីការរំលោភនីតិវិធី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ និងបានប្រកាសនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ២២។

[៤៦] ចូរអានកថាខណ្ឌ ៤៧ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ *Karadžic* ។

[៤៧] ចូរអានកថាខណ្ឌ ៤៧ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ *Karadžic* ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

តម្រូវឲ្យដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការ "បង្ហាញពីតុល្យការនៃភវនីយហេតុដែលថាមានការរំលោភនីតិវិធីមែន" និងការអះអាងថា បទដ្ឋាននេះអាចត្រូវបានបំពេញ ដោយគ្រាន់តែអះអាងថា ការសន្និដ្ឋាននេះ *ទំនងជាមានការពិតច្រើនជាង*ការមិនពិតបែបនេះទេ ដោយសារភវនីយហេតុនេះទាបជាងបទដ្ឋានដែលកំណត់ដោយយុត្តិសាស្ត្រអន្តរជាតិ[៤៨]។

២៦. ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះយល់ស្របតាមយុត្តិសាស្ត្រអន្តរជាតិដែលមានពីមុន ដែលបញ្ជាក់ថា ដើម្បីអាចយកទ្រឹស្តីស្តីពីការរំលោភនីតិវិធីមកប្រើបាន "ជាចាំបាច់ត្រូវតែបង្ហាញថា មានការរំលោភជាក់ស្តែងលើសិទ្ធិរបស់ជនជាប់ចោទ"[៤៩]។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ក្នុងរឿងក្តីដែលខ្លួនបានទទួលនេះ ភាគីគ្មានភស្តុតាងផ្ទាល់ណាមួយគាំទ្រការចោទប្រកាន់របស់ខ្លួនថាការបំពាននេះកើតចេញពីកង្វះអនាគតិ ឬសុចរិតភាពរបស់ចៅក្រម ឬស្ថាប័នរបស់ចៅក្រមទេ ដូចជាបណ្តឹងដែលអង្គជំនុំជម្រះទទួលបានភស្តុតាងដោយផ្ទាល់អាចមិនមានទេ ជាពិសេស នៅពេលបញ្ជាក់ពីចេតនារបស់ម្ចាស់នៃការបំពាននោះ។ ដូច្នេះ ក្នុងករណីដែលគ្មានការទទួលស្គាល់ពីបុគ្គលដែលរងការចោទប្រកាន់ពីភាពលម្អៀង ឬក្នុងករណីដែលគ្មានភស្តុតាងប្រយោលជាបង្អែក ដើមបណ្តឹងឧទ្ធរណ៍មិនអាចបង្ហាញថាការអះអាងរបស់ខ្លួនជាការពិតបានទេ។ ការយកភស្តុតាងប្រយោលមកអះអាងពីចេតនារបស់ចៅក្រមត្រូវតែផ្អែកលើសេចក្តីសន្និដ្ឋាន ដែលកើតចេញពីភស្តុតាងដែលបានដាក់ជូន។ នៅទីបំផុត អំណាចព្យួរកិច្ចស៊ើបសួរគឺជាអំណាចឆន្ទានុសិទ្ធិដែលពាក់ព័ន្ធទៅនឹងការ

---

[៤៨] ក្នុងរឿងក្តី *Miller ទល់នឹង រដ្ឋមន្ត្រីទទួលបន្ទុកសោធននិវត្តន៍* ចៅក្រម Denning បានបញ្ជាក់យ៉ាងខ្លីថា "ត្រូវមានភវនីយហេតុថាពិតច្រើនជាងមិនពិត" ចូរអានរឿងក្តី *Miller ទល់នឹង រដ្ឋមន្ត្រីទទួលបន្ទុកសោធននិវត្តន៍* [1947] 2 All ER 372។

[៤៩] *ក្នុងងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Florence Hartman* IT-02-54-R77.5, "សំអាងហេតុនៃសេចក្តីសម្រេចលើសំណើមេធាវីការពារសុំផ្អាកដំណើរការនីតិវិធីដោយមូលហេតុរំលោភនីតិវិធី" នៃក្រុមប្រឹក្សាជំនុំជម្រះ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩ ជាពិសេស កថាខណ្ឌ ៤។ ចូរអានកថាខណ្ឌ ១១១ នៃសេចក្តីសម្រេច *Nikolic* ដែលយោងទៅរកសេចក្តីសម្រេច *Baraygwiza* កថាខណ្ឌ ៧៣, ៧៧ និង ចូរអានរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Radovan Karadžic* IT-95-5/18-AR73.4, "សេចក្តីសម្រេចលើដំណើរសុំលើកលែងការចោទប្រកាន់ ដោយការរំលោភលើនីតិវិធី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ៩ ផងដែរ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

វាយតម្លៃរបស់តុលាការថាតើការបំពានលើសិទ្ធិរបស់ជនត្រូវចោទ ឬជនជាប់ចោទនោះ មានលក្ខណៈធ្ងន់ធ្ងរដែលនាំឲ្យរាំងស្ទះការអនុវត្តយុត្តាធិការដែរឬទេ[៥០]។

២៧. ផ្អែកតាមការពិចារណាខាងលើនេះ អង្គបុរេជំនុំជម្រះនឹងត្រូវពិចារណាថាតើមានការបំពានធ្ងន់ធ្ងរ ឬការរំលោភជាក់ស្តែងលើសិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ដែរឬទេ។ ត្រូវតែមានភស្តុតាងធ្វើឲ្យអង្គបុរេជំនុំជម្រះជឿជាក់ថា កំហុសឆ្គងដែលរងការចោទប្រកាន់នោះពិតជាកើតចេញពីការរំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយការរំលោភបំពាននេះមានលក្ខណៈធ្ងន់ធ្ងរ ទើបអង្គបុរេជំនុំជម្រះអាចសម្រេចព្យួរកិច្ចស៊ើបសួរជាអចិន្ត្រៃយ៍បាន។

---

[៥០] *ក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Thomas Lubanga Dyilo ICC-01/04-01/06 (OA4), "សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Thomas Lubanga Dyilo* ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីលើយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៩" នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ២៨។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង បានទទួលបណ្តឹងដែលបានសម្រេចពន្យារនីតិវិធីដោយគ្មានលក្ខខណ្ឌ ហើយបង្គាប់ឲ្យដោះលែងជនជាប់ចោទ (សូមអាន *ក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Thomas Lubanga Dyilo *ICC-01/04-01/06* "សេចក្តីសម្រេចសាធារណៈកោសល្យបលើសំណើបន្ទាន់របស់រដ្ឋអាជ្ញាសម្រាប់ការប្រែប្រួលពេលវេលាកំណត់ ដើម្បីបង្ហាញអត្តសញ្ញាណរបស់អន្តរការីចំនួន១៤៣នាក់ ឬជាជម្រើសវិញ ព្យួរនីតិវិធីដើម្បីពិគ្រោះយោបល់បន្ថែមទៀតជាមួយ VWU" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០)។ ប៉ុន្តែសេចក្តីបង្គាប់នេះ អាចត្រូវប្តឹងឧទ្ធរណ៍។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាត្តិតាមពាក្យសុំរបស់រដ្ឋអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចព្យួរនីតិវិធី (សូមអាន ក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo ICC-01/04-01/06-T-314 "ប្រតិចារឹកសវនាការ" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ទំព័រ១៥ បន្ទាត់១៥-២២)។ ឧទាហរណ៍នៃការបំពានដែលនាំឲ្យមានការព្យួរនីតិវិធីដោយសារមានការបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជនជាប់ចោទ សូមអាន សេចក្តីសម្រេចសាលាឧទ្ធរណ៍ក្រុងប៉ារីស Chambre d'Áccusation ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៨៣, 1944/83 (ត្រូវបានស្គាល់ផងដែរ "L'affaire des Irlandais de Vincennes") ដែលអាចរកបានក្នុងបណ្ណាល័យរបស់ អវតក) ដែលតុលាការបានមោឃៈនីតិវិធី និងបញ្ចប់រឿងក្តី ដោយពិចារណាលើភាពជាក់ស្តែង និងធ្ងន់ធ្ងរនៃវិការៈនីតិវិធីដែលបានបង្ហាញ (ចំពោះភាពខុសគ្នារវាងមោឃភាពនីតិវិធី ដោយសារវិការៈនីតិវិធី និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយសាររំលោភលើទ្រឹស្តីនីតិវិធី សូមមើល សាលដីកាសាធារណៈលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ D263/2/6 កថាខណ្ឌ ២៦-២៧។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C.

២៨. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ការបំពានលើសិទ្ធិជនជាប់ចោទមិនមានលក្ខណៈធ្ងន់ធ្ងររហូតដល់នាំឲ្យរាំងស្ទះការអនុវត្តយុត្តាធិការឡើយ[៥១]។ តាមពិតតុលាការអាចព្យួរនីតិវិធី (ដែលជាវិធានការចុងក្រោយ) ដែលត្រូវយកមកអនុវត្តតែក្នុងករណីពិសេស និងករណីមានការរំលោភធ្ងន់ធ្ងរលើសិទ្ធិជនត្រូវចោទដែលមិនអាចជួសជុលបាន ឬបំពានទៅលើស្មារតីយុត្តិធម៌របស់តុលាការតែប៉ុណ្ណោះ។ មានតែករណីពិសេសដែល *ការបំពានមានលក្ខណៈធ្ងន់ធ្ងរទេ* ទើបតុលាការអាចចាត់ទុកថាដំណោះស្រាយនេះត្រឹមត្រូវ នេះជាមូលហេតុដែលតម្រូវឲ្យយកបទដ្ឋានយ៉ាងខ្ពស់មកប្រើដើម្បីកំណត់ថាមាន ឬគ្មានការរំលោភបំពាន និងដើម្បីកំណត់ថាតើការបំពាននោះធ្ងន់ធ្ងរគ្រប់គ្រាន់ដែលតម្រូវឲ្យប្រើដំណោះស្រាយនេះដែរឬទេ[៥២]។ ក្នុងរឿងក្ដីនេះ និងក្នុងបរិបទ អ.វ.ត.ក អង្គបុរេជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិក្នុងការកំណត់តុល្យភាពដែលត្រឹមត្រូវរវាងសិទ្ធិ

---

[៥១] កថាខណ្ឌ ១១៤ នៃសេចក្ដីសម្រេច *Nikolic*។ សាលាឧទ្ធរណ៍បានតម្កល់សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង។ ចូរអាន *ក្នុងរឿងក្ដីរដ្ឋអាជ្ញាទល់នឹង Dragan Nikolic* IT-94-2-AR73, "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ចាត់របៀបស្ដីពីការចាប់ខ្លួន" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ ("សាលដីកា *Nikolic*") កថាខណ្ឌ ៣១។ ចូរអានរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžic* IT-95-5/18-T, "សេចក្ដីសម្រេចលើដំណើរសុំព្យួរនីតិវិធី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៣ ផងដែរ ដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ទោះបីជនជាប់ចោទមានភស្តុតាងខាងអង្គហេតុគាំទ្រការចោទប្រកាន់ក៏ដោយ ក៏ការចោទប្រកាន់នោះមិនជំរុញឲ្យប្រើទ្រឹស្ដីស្ដីពីការរំលោភនីតិវិធី ដើម្បីជាយុត្តិកម្មសម្រាប់ព្យួរនីតិវិធីប្រឆាំងនឹងជាប់ចោទចោទឡើយ។

[៥២] សាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា "ទោះបីជាការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃការបំពានលើសិទ្ធិមនុស្សអាស្រ័យទៅតាមកាលៈទេសៈរឿងក្ដីនីមួយៗ និងមិនអាចសម្រេចបាន*តាមទស្សនទានក៏ដោយ* ក៏ការបំពានសិទ្ធិមនុស្សខ្លះមានលក្ខណៈធ្ងន់ធ្ងរ ដែលតម្រូវមិនឲ្យតុលាការអនុវត្តយុត្តាធិការផងដែរ។ វាអាចមិនសមស្របបើតុលាការកាត់សេចក្ដីជនរងគ្រោះពីការបំពានបែបនេះ។ *ទោះជាយ៉ាងណាក៏ដោយ ក្រៅពីករណីពិសេសបែបនេះ សាលាឧទ្ធរណ៍បានបញ្ជាក់ថា តាមធម្មតា ការសម្រេចមិនអនុវត្តយុត្តាធិការ គឺមិនត្រឹមត្រូវទេ។* ដូច្នេះ តុលាការត្រូវតែធានាតុល្យភាពរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍ពិសេសរបស់សហគមន៍អន្តរជាតិ ក្នុងការកាត់សេចក្ដីបុគ្គលដែលរងការចោទប្រកាន់ពីការបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ" (សេចក្ដីបញ្ជាក់) កថាខណ្ឌ ៣០ នៃសាលដីកា *Nikolic* (លុបលេខយោងចោល)។ ចូរអាន សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងរឿងក្ដី *Lubanga* ផងដែរ ដែលក្នុងនោះអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "មិនមែនគ្រប់ការបំពានលើច្បាប់ ឬការរំលោភលើសិទ្ធិជនជាប់ចោទ ក្នុងដំណាក់កាលចោទប្រកាន់បុគ្គលនោះ សុទ្ធតែជាយុត្តិកម្មគាំទ្រការព្យួរនីតិវិធីនោះឡើយ។ លុះត្រាតែការកាត់សេចក្ដីជនជាប់ចោទប្រាកដជាមានអំពើខុសច្បាប់ដែលនាំឲ្យនីតិវិធីនោះក្លាយទៅជាគ្មានប្រយោជន៍ ដែលគួរឲ្យស្អប់ខ្ពើមទេ ទើបតុលាការអាចព្យួរនីតិវិធីបាន" (កថាខណ្ឌ ៣០)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ជាមូលដ្ឋានរបស់ជនត្រូវចោទ និងផលប្រយោជន៍សហគមន៍ជាតិនិងអន្តរជាតិ ក្នុងការកាត់សេចក្តីជនដែលរងការចោទប្រកាន់ពីការបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ជាតិ។

## V. បញ្ហាអង្គសេចក្តី

២៩. អង្គបុរេជំនុំជម្រះសង្កេតឃើញតាំងពីដំបូងថា ការចោទប្រកាន់ដែលលើកឡើងក្នុងសំណើសុំស្តីពីការរំលោភនីតិវិធី គឺដូចគ្នាបេះបិទទៅនឹងការចោទប្រកាន់ ដែលសហមេធាវីការពារក្តីជនត្រូវចោទបានលើកឡើងក្នុងបណ្តឹងជំទាស់ និងបណ្តឹងសុំឱ្យធ្វើមោឃភាពរួចហើយ។ បន្ទាប់ពីនោះមក អង្គបុរេជំនុំជម្រះក៏បានពិចារណា និងសម្រេចបញ្ហាទាំងនោះក្នុងបរិបទទាំងនេះរួចអស់ហើយ[៥៣]។

៣០. នៅក្នុងសំណើ និងបណ្តឹងពីមុនរបស់ខ្លួន សហមេធាវីការពារក្តីជនត្រូវចោទបានអះអាងថា មាន "ភាពមិនប្រក្រតី និងការរំលោភបំពានជាច្រើនដែលអាចនាំឱ្យ" គេមិនអាចយល់ថា កិច្ចស៊ើបសួររបស់ ក.ស.ច.ស "មានយុត្តិធម៌ អព្យាក្រឹត្យ និងគ្មានលម្អៀងបានទេ"[៥៤]។ សហមេធាវីការពារក្តីជនត្រូវចោទកំពុងព្យាយាមស្នើឱ្យអង្គបុរេជំនុំជម្រះពិចារណាផលវិបាក នៃមូលហេតុទាំងនេះ ដោយអះអាងថា "ការរំលោភបំពាន និងភាពមិនប្រក្រតីមានលក្ខណៈ/វិសាលភាពធំធេងនិងធ្ងន់ធ្ងរខ្លាំង និងមិនអាចជួសជុលបានឡើយ"[៥៥]។

---

[៥៣] សាលដីកាលើសំណើសុំឱ្យធ្វើមោឃភាព សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំឱ្យចាត់វិធានការសមស្របពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រឆាំងនឹងឯករាជភាពរបស់ចៅក្រម Katinka Lahuis និង Rowan Downing ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ 002/20/-10-2009-ECCC/OCIJ (PTC03), ឯកសារលេខ ៥ ERN 00404595-00404601 ("សេចក្តីសម្រេចលើវិធានការសមស្រប"), សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់លោក នួន ជា ប្រឆាំងនឹងចៅក្រម Marcel Lemonde ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ 002/29-10-2009-ECCC/OCIJ (PTC04), ឯកសារលេខ ៤ ERN 00485317-00485329 ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់លោក នួន ជា"), សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់លោក អៀង សារី និង អៀង ធីរិទ្ធ តាមមាត្រា ៣៤ ប្រឆាំងនឹងចៅក្រម Marcel Lemonde ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ 002/07-12-2009-ECCC/OCIJ (PTC05&07), ឯកសារលេខ ៨ និង ៥ ERN 00520708-00520708 ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់លោក អៀង សារី និង អៀង ធីរិទ្ធ") ។

[៥៤] សំណើសុំស្តីពីការរំលោភលើនីតិវិធី កថាខណ្ឌ ៥៨។

[៥៥] សំណើសុំស្តីពីការរំលោភលើនីតិវិធី កថាខណ្ឌ ៦១។

00582603



៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីស្នើសុំឱ្យព្យួរកិច្ចស៊ើបសួរផ្អែកលើទ្រឹស្តីស្តីពីការរំលោភនីតិវិធី ទោះបីជាខ្លួនបានបញ្ជាក់ដដែលៗថា តុលាការអាចព្យួរនីតិវិធីបាន "ដរាបណា ឬរហូតទាល់តែកង្វះអនាគតិ និងកង្វះឯករាជ្យភាព និងភាពមិនប្រក្រតី *មិនអាចជួសជុលបាន*"[៥៦] (សេចក្តីបញ្ជាក់បន្ថែម)។ មោឃភាពនីតិវិធីគឺជាវិធីជួសជុលភាពមិនប្រក្រតីក្នុងនីតិវិធី ឯការព្យួរកិច្ចស៊ើបសួរដោយផ្អែកលើទ្រឹស្តីស្តីពីការរំលោភនីតិវិធី ក្នុងករណីដែលបានស្នើនេះមិនមែនជាការជួសជុលកំហុសនីតិវិធីឡើយ។ តាមការពិចារណាខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ការរំលោភបំពានដែលបានលើកឡើងក្នុងសំណើស្តីពីការរំលោភនីតិវិធីនេះ គឺជាមូលដ្ឋាននៃសំណើ (របស់មេធាវី) សុំព្យួរកិច្ចស៊ើបសួរដោយសារមានការរំលោភនីតិវិធី។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងអនុវត្តបទដ្ឋាននៃការផ្តល់ភស្តុតាង ដូចបានកំណត់ក្នុងសាលដីកានេះ និងត្រូវពិចារណាថាតើដើមបណ្តឹងឧទ្ធរណ៍ទទួលរងការបំពានធ្ងន់ធ្ងរកម្រិតណា ឬថាតើមានការបំពានជាក់ស្តែងលើសិទ្ធិរបស់ជនត្រូវចោទដែរទេ។

៣២. សហមេធាវីការពារក្តីបានលើកឡើងថា "សម្រាប់សម្រាប់គោលបំណងសំណើនេះ *ការចោទប្រកាន់ដែលបានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍ទាំងពីររបស់លោក Bastin នឹងត្រូវបានសន្និដ្ឋានថាជាការពិត*" (សេចក្តីបញ្ជាក់បន្ថែម)[៥៧]។ តាមពិតសហមេធាវីការពារក្តីពិតជាបានពឹងផ្អែកលើសេចក្តីថ្លែងការណ៍ពីររបស់លោក Bastin ដែលជាអតីតបុគ្គលិក ក.ស.ច.ស ដែលបានធ្វើឡើងនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២00៩ និងថ្ងៃទី២ ខែធ្នូ ឆ្នាំ២00៩ ដើម្បីអះអាងថា ការចោទប្រកាន់ក្នុងបណ្តឹងនេះបង្កើតបានជាការរំលោភសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយនាំឱ្យមានការបំពានធ្ងន់ធ្ងរលើនីតិវិធី ដែលបណ្តាលឱ្យមានការព្យួរកិច្ចស៊ើបសួរ។

៣៣. ដូចដែលបានបញ្ជាក់ខាងលើ មានតែការបំពានជាក់ស្តែងដែលមានភស្តុតាងច្បាស់លាស់ទេ ទើបអាចជាមូលដ្ឋានដែលនាំឱ្យអង្គបុរេជំនុំជម្រះយល់ថា មានការចាំបាច់ក្នុងការព្យួរនីតិវិធី ដោយសារការបំពាននីតិវិធីបាន រឺឯ*ការសន្និដ្ឋានពីការពិត* របស់អតីតបុគ្គលិកតុលាការ ដែលសហមេធាវីការ

[៥៦] សំណើសុំស្តីពីការរំលោភលើនីតិវិធី កថាខណ្ឌ ៣៧, ៤២ និង៦0។

[៥៧] សំណើសុំស្តីពីការរំលោភលើនីតិវិធី កថាខណ្ឌ ៥។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ពារក្តីយល់ថាជាការបំពានលើសិទ្ធិជនត្រូវចោទ ហើយអាចជាយុត្តិកម្មគាំទ្រការព្យួរនីតិវិធី (ដែលជាដំណោះស្រាយដាច់ខាត) នោះ មិនមែនជាមូលដ្ឋានសមស្របឡើយ។

៣៤. សហមេធាវីការពារក្តីបានលើកឡើងថា សេចក្តីថ្លែងការណ៍ និងឥរិយាបថរបស់ចៅក្រម Marcel Lemonde បង្កើតបានជាការបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ហើយក៏ជាការបំពានលើនីតិវិធីផងដែរ។ ប៉ុន្តែ ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញភស្តុតាងណាផ្សេងពីសេចក្តីថ្លែងការណ៍*ដែលខ្លួនសន្និដ្ឋានថាជាការពិត* ដើម្បីជាភស្តុតាងគាំទ្រការអះអាងរបស់ខ្លួនថាមានកំហុសឆ្គងនេះឡើយ។

៣៥. លើសពីនេះទៅទៀត ដូចបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចលើការចោទប្រកាន់ទាំងនោះរួចហើយនៅក្នុងសាលដីកាលើសំណើសុំឱ្យធ្វើមោឃភាព និងបណ្តឹងជំទាស់ដិតចិត្តរបស់សហមេធាវីការពារក្តី។ អង្គបុរេជំនុំជម្រះបានបដិសេធចោលការចោទប្រកាន់ពីភាពលម្អៀងរបស់ចៅក្រម Marcel Lemonde ផ្អែកតាមសេចក្តីថ្លែងការណ៍របស់លោក Bastin ព្រមទាំងការចោទប្រកាន់ពាក់ព័ន្ធនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចលើឃ្លាំងផ្ទុកឯកសាររួមដែលបញ្ជាក់ក្នុងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ដោយផ្អែកលើមូលដ្ឋាននៃកង្វះភស្តុតាង ដែលមិនបានបំពេញតាមបទដ្ឋានដ៏ខ្ពស់សម្រាប់បដិសេធចោលសេចក្តីសន្និដ្ឋានពីអនាគតិក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង ឬដើម្បីសម្រេចមោឃភាពនីតិវិធីដូចបានចែងក្នុងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង[៥៨]។ អង្គបុរេជំនុំជម្រះបានរកឃើញថា ការចោទប្រកាន់នៅក្នុងសេចក្តីថ្លែងការណ៍របស់លោក Bastin គឺគ្រាន់តែជាការសន្និដ្ឋាន ហើយសហមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពី*អត្ថិភាព* នៃកង្វះឯករាជភាព កង្វះអនាគតិ ឬសុចរិតភាព ដែលអាចជាមូលដ្ឋាននៃការអះអាងរបស់ដើមបណ្តឹងឧទ្ធរណ៍ថា មានការបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដែលតម្រូវឱ្យយកទ្រឹស្តីស្តីពីការរំលោភនីតិវិធីមកអនុវត្តឡើយ[៥៩]។

[៥៨] សេចក្តីសម្រេចលើសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ ២៩-៥៦។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ដិតចិត្តរបស់ អៀង សារី និង អៀង ធីរិទ្ធ កថាខណ្ឌ ៤០-៤៦។

[៥៩] សេចក្តីសម្រេចលើសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ ៤០-៤១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៣៦. ក្នុងបណ្តឹងនេះ សម្រាប់ដើមបណ្តឹងឧទ្ធរណ៍បានផ្តល់ភស្តុតាងដដែលសម្រាប់គាំទ្រការចោទប្រកាន់ដដែល ហើយភស្តុតាងដដែលនេះមិនបំពេញតាមបទដ្ឋានដ៏ខ្ពស់ ដែលអនុវត្តចំពោះការពិនិត្យការចោទប្រកាន់ពីការបំពាននីតិវិធីឡើយ។ ដោយសារដើមបណ្តឹងឧទ្ធរណ៍មិនបានលើកបញ្ហាអ្វីថ្មី អង្គបុរេជំនុំជម្រះនឹងមិនលើកបញ្ហាដែលខ្លួនបានសម្រេចរួចហើយមកពិចារណាឡើងវិញឡើយ។

៣៧. ពាក់ព័ន្ធនឹងការចោទប្រកាន់ពីការរំលោភលើសិទ្ធិជនត្រូវចោទ ផ្អែកតាមការសន្និដ្ឋានថាសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីគឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ សហមេធាវីការពារក្តីបានអះអាងថា ខ្លួនមិនអាចទុកចិត្តថាសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌របស់ជនត្រូវចោទត្រូវបានគោរព ឬភស្តុតាងពាក់ព័ន្ធទាំងអស់ត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមទៅតាមវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ១៣ នៃកិច្ចព្រមព្រៀងឡើយ។

៣៨. អង្គបុរេជំនុំជម្រះក៏បានសម្រេចលើបញ្ហាទាំងនេះរួចហើយ ក្នុងសេចក្តីសម្រេចពីមុន ដែលក្នុងនោះខ្លួនបានសម្រេចថាសេចក្តីថ្លែងការណ៍របស់បុគ្គលដែលសារព័ត៌មានបានដកស្រង់ មិនមែនជាភស្តុតាងអាចជឿជាក់បានទេ ហើយអង្គបុរេជំនុំជម្រះក៏បានបដិសេធបណ្តឹងផិតចិត្តដែលផ្អែកលើភស្តុតាងបែបនេះដែរ[៦០]។ ដោយសារមាត្រា ៣៥ បានចែងពីយន្តការសមស្របសម្រាប់ដោះស្រាយការចោទប្រកាន់ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការចោទប្រកាន់ពីការរំលោភនីតិវិធីបែបនេះ អាចនឹងនាំឱ្យមានការព្យួរកិច្ចស៊ើបសួរ តែក្នុងករណីដែលការបំពាននោះធ្ងន់ធ្ងរខ្លាំង មិនអាចជួសជុលបានតាមបទប្បញ្ញត្តិវិធាន ៣៥(២)នៃវិធានផ្ទៃក្នុង។ សហមេធាវីការពារក្តីបានអះអាងបន្ថែមទៀតថា សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី "ត្រូវតែសន្មតថា អាចឱ្យជឿទុកចិត្តបាន" (សេចក្តីបញ្ជាក់បន្ថែម)[៦១]។ ដូច្នេះ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់គាំទ្រការចោទប្រកាន់នេះទេ ហើយក៏មិនយល់ឃើញថា អំពើដែលបានចោទប្រកាន់នេះគឺជាការរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទដែលអាចនាំឱ្យយកទ្រឹស្តីស្តីពីការបំពាននីតិវិធីមកអនុវត្តបានឡើយ។

---

[៦០] សេចក្តីសម្រេចលើបណ្តឹងផិតចិត្តរបស់លោក ខៀវ សំផន ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត Marcel Lemonde ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ សំណុំរឿង: ០០២/១៣-១០-២០០៩-អវតក/អបជ(០២), ឯកសារលេខ ៧ កថាខណ្ឌ ៣០។

[៦១] សំណើសុំស្តីពីការរំលោភនីតិវិធី កថាខណ្ឌ ៤៧។



ECCC CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៣៩. តាមរយៈការពិនិត្យលើអង្គហេតុទាំងអស់ដែលជនត្រូវចោទបានដាក់ជូន សម្រាប់គាំទ្រសំណើសុំស្ដីពីការរំលោភនីតិវិធី អង្គបុរេជំនុំជម្រះរកឃើញថា គ្មានភស្តុតាងពីការរំលោភលើសិទ្ធិមនុស្សរបស់ជនត្រូវចោទ ហើយក៏គ្មានភស្តុតាងបញ្ជាក់ថាមានការបំពានលើគោលការណ៍មូលដ្ឋានស្ដីពីនីតិវិធីត្រឹមត្រូវតាមច្បាប់ផងដែរ។ គ្មានភស្តុតាងណាមួយក្នុងសំណើសុំស្ដីពីការរំលោភនីតិវិធីដែលបង្ហាញថាមានការរំលោភនីតិវិធីក្នុងករណីនេះឡើយ។ ដូច្នេះ គ្មានបញ្ហានៃការបំពានធ្ងន់ធ្ងរលើសិទ្ធិរបស់ជនត្រូវចោទដែលអាចឲ្យយកទ្រឹស្ដីស្ដីពីការរំលោភនីតិវិធីមកប្រើ ដើម្បីសម្រេចព្យួរនីតិវិធីបានទេ។ អង្គបុរេជំនុំជម្រះរកឃើញថា ទឡ្ហីករណ៍នីមួយៗ ឬទាំងអស់ដែលសហមេធាវីការពារក្ដីបានលើកឡើងក្នុងសំណើសុំស្ដីពីការបំពាននីតិវិធីនោះ មិនបង្កើតបានជាការបំពាននីតិវិធីឡើយ។

ផ្អែកតាមសំអាងហេតុដូចបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះក្នុងសាលដីការបស់ខ្លួនដែលប្រកាសនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING** **ន័យ ថុល** **Catherine MACHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គីមសាន**